

ចូរអនុញ្ញាតឲ្យព្រះគ្រប់គ្រង



(5)

នេះគឺជាពាក្យរបស់លោក ដេ រិក ព្រីនស៍
ដែលបានដកស្រង់ពីព្រះបន្ទូលនៃព្រះសម្រាប់លោកអ្នក។

> ឥឡូវនេះ ឯពួកអ្នកដែលថា ថ្ងៃនេះ ឬថ្ងៃស្អែក
> យើងនឹងទៅឯក្រុងណាមួយ
> ហើយនឹងនៅស្រុកនោះអស់១ឆ្នាំ
> ដើម្បីនឹងរកស៊ីឲ្យបានចំណេញ
> អ្នករាល់គ្នាមិនដឹងជានឹងកើតមានយ៉ាងណាដល់ថ្ងៃស្អែកទេ
> ត្បិតជីវិតអ្នករាល់គ្នាជាអ្វី គឺជាចំហាយទឹកទេតើ
> ដែលឃើញតែ១ភ្លែត រួចបាត់ទៅ។ [យ៉ាកុប ៤:១៣-១៤]

តើអ្នកមិនបានស្គាល់មនុស្សជាច្រើនដែលនិយាយដូច្នោះទេ?
ពួកគេគ្រោងធ្វើដោយមានទំនុកចិត្តសម្រាប់ឆ្នាំនេះ នៅឆ្នាំក្រោយ
ដែលពួកគេនឹងធ្វើអាជីវកម្ម
កន្លែងដែលពួកគេនឹងវិនិយោគប្រាក់របស់ពួកគេ
កន្លែងដែលពួកគេនឹងចំណាយពេលវិស្សមកាលរបស់ពួកគេ
រយៈពេលប៉ុន្មានដែលពួកគេនឹងចំណាយពេលនៅទីនេះ និងទីនោះ
និងជាច្រើនដងមកហើយ ដែលពួកគេរៀបចំផែនការច្រើនឆ្នាំជាមុន
សម្រាប់ការចូលនិវត្តន៍របស់ពួកគេ
និងកន្លែងដែលពួកគេនឹងចំណាយពេលនៃការចូលនិវត្តន៍របស់ពួកគេ
។

ប៉ុន្តែពួកគេបានភ្លេចពីសេចក្តីពិតមួយដែលថាពួកគេមិនអាចត្រួតត្រា
ឬគ្រប់គ្រងលើការទាំងនោះបានទេ។
ពាក្យព្រះបន្ទូលដែលខ្ញុំបានអានប្រាប់ដល់អ្នក និយាយថា
ត្បិតជីវិតអ្នករាល់គ្នាជាអ្វី គឺជាចំហាយទឹកទេតើ ដែលឃើញតែ១ភ្លែត
រួចបាត់ទៅ។ តើល្ងីល្ងើដល់ម្ល៉េះដែលចំហាយទឹកធ្វើផែនការដូច្នោះ។
តើអ្វីទៅជាដំណោះស្រាយ? ផ្ទុយទៅវិញ
អ្នកគួរតែបាននិយាយដូច្នេះវិញថា

> បើយើងរស់នៅ
> ហើយព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យនោះ
> យើងនឹងធ្វើការនេះ ឬការនោះ។

ចំហាយទឹក (អ័ព្ទ)
នោះមិនអាចគ្រប់គ្រងលើកន្លែងដែលវានៅនោះទេ។
ប្រសិនបើព្រះអាទិត្យរះឡើងវានឹងរលាយ។ បើខ្យល់បក់
វានឹងត្រូវជាត់នាំទៅឆ្ងាយ។ អ្នកឃើញទេ
អ្នកត្រូវតែពឹងផ្អែកទាំងស្រុងទៅលើព្រះសម្រាប់គ្រប់ដង្ហើមដែលអ្នកដក
សម្រាប់គ្រប់ជំហានីមួយៗដែលអ្នកត្រូវឈាន។

© 1970 — Derek Prince Ministries - International®

កុំរៀបចំគម្រោងដោយគ្មានព្រះនៅក្នុងជីវិតរបស់អ្នក។ កុំល្ងង់ពេក។
គ្រាន់តែបន្ទាបខ្លួនអ្នកមួយភ្លែត
ហើយទទួលស្គាល់ថានោះហើយគឺជារូបអ្នក។
អ្នកគ្រាន់តែជាអ័ព្ទដែលលេចមកនៅរយៈពេលខ្លីមួយ
នៅក្នុងចំហាយទឹក ហើយបន្ទាប់មកអ្នកនឹងត្រូវរលាយបាត់
និងត្រូវបានជាត់ចេញទៅឆ្ងាយ។ ចូរទទួលយកព្រះមកគ្រប់គ្រង។
ចូររៀបចំគម្រោងការដោយមានព្រះជាម្ចាស់នៅក្នុងចិត្តគំនិតរបស់អ្នក
ហើយព្រះជាម្ចាស់នឹងទតមើលវាថាផែនការរបស់អ្នកនៅជាប់រឹងមាំ។

: WD-WFTW-005-KHM
: 24 Feb 2026
: derekprince.com/km/resources

